# ខ្លឹមសារ
# សង្ខេប
# ច្បាប់ ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតនៅភាពអាសន្ន (ឆ្នាំ ២០២០)

http://www.measboralaws.com/detail/1086

១. ច្បាប់នេះកំណត់នីតិវិធី នៃការដាក់ប្រទេសជាតិក្នុងភាពអាសន្ន ក្នុងគោលបំណង ការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ..(មាត្រា ១)។

២. ការដាក់ប្រទេសក្នុងស្ថានភាពនេះ អាចបណ្តាលមកពី សង្គ្រាម...ការឆ្លងរាលដាលនៃជំងឺ ប៉ះពាល់ដល់សុខភាពសាធារណៈ...(មាត្រា ៤)។ ព្រះមហាក្សត្រ ប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន តាមព្រះរាជក្រឹត្យ ក្រោយពី មានការឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានសភា និងព្រឹទ្ធសភា។ រយៈពេលដាក់ប្រទេសក្នុងភាពអាសន្ន មានរយៈពេល ៣ខែ និងអាចបន្តបន្ថែម ឬបញ្ចប់មុនកាលបរិច្ឆេទកំណត់។ ស្ថានភាពនេះ អាចត្រូវបានប្រកាសបញ្ចប់មុនកាលកំណត់ ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។ រដ្ឋសភា ឬព្រឹទ្ធសភា មានសិទ្ធិបញ្ចប់កាលៈទេសៈ ដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន កាលបើសភាពការណ៍អនុញ្ញាត...(មាត្រា ៣)។

៣. ជាការឆ្លើយតប រាជរដ្ឋាភិបាល មានសិទ្ធិ និងអំណាចដាក់ចេញវិធានការជាច្រើនមួយចំនួន ឆ្លុះបញ្ចាំងដោយ ពាក្យ «ដូចខាងក្រោម» និង ...«វិធានការដទៃទៀតដែលសមស្របនិងចាំបាច់»....។ វិធានទាំងនោះ មានការកម្រិតសិទ្ធិ (ការជួបប្រជុំ) និងវិធានប្រតិបត្តិមួយចំនួន។ មាត្រា ៥ ទំនងជាស្នើថា ក្នុងករណីវិធានទាំងនេះ មិនគ្រប់គ្រាន់ រាជរដ្ឋាភិបាលអាច គ្រប់គ្រងប្រទេស តាមរបបអាជ្ញាសឹកបាន (មាត្រា ៥)។

៤. រដ្ឋសភា និងព្រឹទ្ធសភា អាចត្រួតពិនិត្យ និងវាយតម្លៃអំពីវិធានការ ដែលបានដាក់ចេញ តាមរយៈការពិនិត្យលើរបាយការណ៍ជាប្រចាំ របស់រាជរដ្ឋាភិបាល ដាក់ជូនស្ថាប័នទាំងពីរនេះ។ ច្បាប់បានដាក់ទោសប្បញ្ញត្តិ ដល់មន្ត្រីមានសមត្ថកិច្ច ដែលប្រើប្រាស់អំណាចតាមទំនើងចិត្ត ប៉ះពាល់ដល់រូបកាយ ឬទ្រព្យសម្បត្តិបុគ្គលដទៃ (មាត្រា ១០) និងដាក់ទោសបុគ្គល ព្រមទាំង នីតិបុគ្គល ដែល មានចេតនារារាំងដល់កិច្ចប្រតិបត្តិការឆ្លើយតប ឬមានចេតនាមិនគោរពវិធាន ចែងក្នុងមាត្រា ៥។ ទោស រួមមានពិន័យ និងពន្ធនាគារ ១ ខែ ទៅ ១ ឆ្នាំ ឬ ៥ឆ្នាំ ទៅ ១០ ឆ្នាំ តាមប្រភេទបទល្មើស ព្រមទាំងទោសបន្ថែម ផងដែរ (មាត្រា ៧ ដល់មាត្រា ៩)។

ដើម្បីទទួលបានព័ត៌មានកាន់តែច្បាស់បន្ថែម សូមអាន សំណួរនិងចម្លើយ ពាក់ព័ន្ធនឹងច្បាប់៖ ក្របខ័ណ្ឌច្បាប់និងនីតិវិធីនៃការដាក់ប្រទេសកម្ពុជាក្នុងភាពអាសន្ន http://www.measboralaws.com/detail/1090 ព្រមទាំងនីតិវិធី និង លក្ខខណ្ឌ ដាក់ប្រទេសក្នុងភាពអាសន្ន អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ http://www.measboralaws.com/detail/1089។